ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# ប្រធានបទសិក្ខាសាលា
# ស្តីពី

# អត្ថប្រយោជន៍នៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា សម្រាប់ សហគ្រាសធុន តូចនិងមធ្យម និងសិប្បកម្ម

## Benefits of registering intellectual property for small and medium enterprises ( SMEs ) and handicrafts.

*ឧទ្ទេសនាមដោយៈ ផៃ ច័ន្ទត្រាវុឌ្ឍ អគ្គនាយកឧស្សាហកម្ម*

ភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២៥

# មាតិកា

I. តើមានអ្វីខ្លះដែលការពារដោយច្បាប់កម្មសិទ្ធិបញ្ញា

II. ស្ថាប័នគ្រប់គ្រងក្នុងការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា

III. មូលដ្ឋានច្បាប់កម្មសិទ្ធិបញ្ញានៅកម្ពុជា

IV. លក្ខខណ្ឌទទួលបានប្រកាសនីយបត្រតក្កកម្ម និងគំនូរឧស្សាហកម្ម និងរយៈពេលការការពារ

V. អត្ថប្រយោជន៍នៃការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា សម្រាប់ សហគ្រាសធុន តូច និងមធ្យម និងសិប្បកម្ម

**I have an A CREATION …. What is the best way to protect it ??**
**How do I make it my intellectual property???**

# I- តើមានអ្វីខ្លះដែលការពារដោយច្បាប់កម្មសិទ្ធិបញ្ញា



**ការការពារពូជថ្មីនៃដំណាំ**
New Plant Varieties Protection

**សញ្ញា រូបសញ្ញាសម្លែកៗ /ឈ្មោះក្រុមហ៊ុន**
Logo/ Distinctive signs /Trade name

**ព័ត៌មានសម្ងាត់មានតម្លៃពាណិជ្ជកម្ម**
Undisclosed information of commercial value

**ភាពច្នៃប្រឌិតថ្មី ផលិតផល/ដំណើរផលិតកម្ម/**
Inventions functional aspects.




**ស្នាដៃសិល្បៈ និងស្នាដៃអក្សរសាស្ត្ររួមទាំងកម្មវិធីកុំព្យូទ័រ និងការប្រមូលទិន្នន័យ**
Cultural, Artistic, and literary works, including computer software and compilation of data

**ការដាក់ឈ្មោះទំនិញដែលមានគុណភាព ឬប្រភពដើមនៃកេរ្តិ៍ឈ្មោះទំនិញ**
Denomination for goods of a given quality or reputation Attributable to the geographical origin

**បន្ទះឈីបអេឡិចត្រូនិក**
Microchips

**ការរចនាច្នៃប្រឌិតម៉ូត និងការតុបតែងរូបរាង ដែលបានអនុវត្តលើផលិតផលឧស្សាហកម្ម**
**Distinctive shapes / ornamentation Applied to articles of manufacture**

# II- ស្ថាប័នគ្រប់គ្រងក្នុងការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា

– កម្ពុជាមានក្រសួងបីទទួលខុសត្រូវក្នុងការចុះបញ្ជីការពារកម្មសិទ្ធិបញ្ញានៅព្រះរាជាណាចក្រកម្ពុជារួមមាន៖

1. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖
   - ប្រកាសនីយបត្រតក្កកម្ម
   - ម៉ូដែលមានអត្ថប្រយោជន៍
   - គំនូរឧស្សាហកម្ម
   - ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ
   - គំនូរបង្ហាញសៀគ្វីបង្រួម







2. ក្រសួងពាណិជ្ជកម្ម៖
   - ពាណិជ្ជសញ្ញា និងពាណិជ្ជនាម
   - ទីតាំងភូមិសាស្ត្រនៃទំនិញ
   - ព័ត៌មានសម្ងាត់មានតម្លៃពាណិជ្ជកម្ម





3. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
   - សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## III- មូលដ្ឋានច្បាប់កម្មសិទ្ធិបញ្ញានៅកម្ពុជា

១. ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៏ និងគំនូរឧស្សាហកម្ម

២. ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់

៣. ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

៤. ច្បាប់ស្តីពីម៉ាកសំគាល់ភូមិសាស្ត្រទំនិញ

៥. ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ

៦. ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម

៧. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ រួមមានប្រកាសអនុវត្តច្បាប់ខាងលើនេះ និងប្រកាសស្តីពីការបង់កម្រៃសេវាសាធារណៈ។

# IV- លក្ខខណ្ឌទទួលបានប្រកាសនីយបត្រតក្កកម្ម និងគំនូរឧស្សាហកម្ម និង រយៈពេលការការពារ




ប្រកាសនីយបត្រតក្កកម្ម (Patent)

តក្កកម្មដែលអាចទទួលប្រកាសនីយបត្រតក្កកម្មបានលុះត្រាតែតក្កកម្មនោះ៖

- ថ្មី (Novelty)
- មានជំហានរកឃើញថ្មី និង(Involves an Inventive Step)
- អាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម (Industrially applicable )

រយៈពេលនៃការការពារ 20 ឆ្នាំ



សំណុំលិខិតស្នើសុំ (Khmer & English)

+ សេចក្តីអត្ថាធិប្បាយ
+ សេចក្តីអះអាង
+ ខ្លឹមសារសង្ខេប
+ គំនូរបង្ហាញ (ប្រសិនបើមាន)

# គំនូរឧស្សាហកម្ម

**-គំនូរឧស្សាហកម្ម ៖** គឺជាការផ្គុំនៃបន្ទាត់ ឬពណ៌ ឬទម្រង់បីខ្នាត ឬសម្ភារៈណាមួយ រំលេចចេញជារូបរាងពិសេសនៃផលិតផល ឧស្សាហកម្ម ឬសិប្បកម្ម និងអាចសំគាល់បាន ដោយភ្នែក។












*-លក្ខខណ្ឌដែលអាចចុះបញ្ជីបាន គឺៈ - ថ្មី*

**-គំនូរឧស្សាកម្មដែលមិនអាចចុះបញ្ជីបានគឺៈ** ផ្ទុយនិងសណ្ដាប់ធ្នាប់សាធារណៈសីលធម៌ សង្គម។

## រយៈពេលការពារ

- ៥ឆ្នាំ ចាប់គិតពីកាលបរិច្ឆេទចុះបញ្ជីគំនូរឧស្សាហកម្ម អាចបន្តបានរយៈពេល៥ឆ្នាំ

+ ៥ឆ្នាំ ជាប់គ្នា (សរុបចំនួន ១៥ឆ្នាំ)

# V- អត្ថប្រយោជន៍នៃការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា សម្រាប់សហគ្រាសធុន តូច និងមធ្យម និងសិប្បកម្ម

**១. ការពារសិទ្ធិនៃទ្រព្យសម្បត្តិបញ្ញា**

- ជួយការពារការច្នៃប្រឌិត និងការបង្កើតថ្មីៗពីការចម្លង ឬប្រើប្រាស់ដោយគ្មានការអនុញ្ញាត
- បង្កើតភាពជឿជាក់ និងសុវត្ថិភាពក្នុងការវិនិយោ

**២. បង្កើនតម្លៃ និងភាពប្រកួតប្រជែង**

- កម្មសិទ្ធិបញ្ញា (ម៉ាកសញ្ញា, រូបសញ្ញា ប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម) ជាឧបករណ៍បង្កើនតម្លៃផលិតផល
- ជួយឲ្យសហគ្រាសមានសក្តានុពល និងអាចប្រកួតប្រជែងបានលើទីផ្សារក្នុងស្រុក និងអន្តរជាតិ

## ៣. ឱកាសធ្វើពាណិជ្ជកម្ម និងវិនិយោគ

- ការចុះបញ្ជីកម្មបញ្ញាជួយបង្កើតភាពជឿជាក់សម្រាប់ដៃគូ និងវិនិយោគិន។
- អាចប្រើជាទ្រព្យសម្បត្តិធានា ក្នុងការទទួលប្រាក់កម្ចី។
- បង្កើនឱកាសក្នុងការចូលរួមគម្រោងសហការណ៍ជាមួយដៃគូអន្តរជាតិ។

## ៤. ផលប្រយោជន៍ផ្នែកទីផ្សារ

- បង្កើតអត្តសញ្ញាណ និងភាពស្គាល់របស់អតិថិជន។
- ជួយសហគ្រាសធ្វើទីផ្សារបានមានប្រសិទ្ធភាព។
- បង្កើនភាពស្មោះត្រង់ និងការទុកចិត្តរបស់អតិថិជន។

## ៥. ការចូលរួមក្នុងអន្តរជាតិ

- ការចុះបញ្ជីកម្មបញ្ញាជួយឲ្យ SMEs និងសិប្បកម្មអាចចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិបានងាយស្រួល។
- ការពារកម្មសិទ្ធិឧស្សាហកម្មនៅក្នុងប្រទេសផ្សេងៗ តាមកិច្ចព្រមព្រៀងអន្តរជាតិ មានភាពងាយស្រួល។
- បង្កើនឱកាសក្នុងការចូលរួមពិព័រណ៌ និងព្រឹត្តិការណ៍អន្តរជាតិ។

## ៦. សារសំខាន់សម្រាប់ SMEs និងសិប្បកម្ម

- ការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម មិនមែនជាការចំណាយបន្ថែមទេ ប៉ុន្តែជាការវិនិយោគដ៏មានតម្លៃ។
- ជួយបង្កើតភាពប្រកួតប្រជែង និងភាពច្នៃប្រឌិត។
- ជាគន្លងសំខាន់ក្នុងការរីកចម្រើនអាជីវកម្មនាពេលអនាគត។

**ការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម គឺជាគន្លងសំខាន់សម្រាប់** SMEs និង សិប្បកម្ម ក្នុងការការពារការច្នៃប្រឌិត បង្កើនភាពប្រកួតប្រជែង និងបង្កើត ឱកាសពាណិជ្ជកម្មថ្មីៗ។ វាជួយបង្កើតភាពជឿជាក់ និងភាពស្ថិរភាព សម្រាប់ការរីកចម្រើនអាជីវកម្មនាពេលអនាគត។





អរគុណ Thank you